*(ការបកប្រែក្រៅផ្លូវការ ពីអត្ថបទបារាំង ដោយគណកម្មាធិការព្រំដែនកម្ពុជា ប្រចាំប្រទេសបារាំង និងក្នុងពិភពលោក)*

# <u>តុលាការអន្តរជាតិ</u>

## សំណុំរឿងប្រាសាទព្រះវិហារ (ការវិនិច្ឆ័យក្នុងសាច់រឿង)

### សាលក្រម ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៦២

*សំណុំរឿងប្រាសាទព្រះវិហារ (ការវិនិច្ឆ័យក្នុងសាច់រឿង) រវាងប្រទេសកម្ពុជានិងប្រទេសថៃឡង់ ត្រូវបានលើកឡើង ដោយពាក្យបណ្តឹងរបស់រដ្ឋាភិបាលប្រទេសកម្ពុជា ។ ទល់នឹងការលើកឡើងលើករណីលើកលែងបឋម* (Exceptions préliminaires) *ពីរយ៉ាងដែលបានធ្វើ ដោយរដ្ឋាភិបាលរបស់ប្រទេសថៃឡង់ ដោយសាលដីកាចុះថ្ងៃទី ២៦ ឧសភា ១៩៦១ តុលាការបានទទួលស្គាល់ថា តុលាការមានសមត្ថកិច្ច វិនិច្ឆ័យពាក្យបណ្តឹងនេះ ។*

*នៅក្នុងសាលក្រមលើសំណុំរឿងនេះផ្ទាល់ (សាច់រឿង) ដោយមានសម្លេង៩ទល់នឹង៣ តុលាការបានសម្រេចថាប្រាសាទព្រះវិហារ ស្ថិតក្នុងទឹកដីនៅក្រោមអធិបតេយ្យភាពរបស់ប្រទេសកម្ពុជា ហើយដោយហេតុនេះ ប្រទេសថៃឡង់ត្រូវដកកងកម្លាំងប្រដាប់អាវុធទាំងអស់ ឬកងប៉ូលិស ឬអ្នកយាមនិងឆ្មាំ ដែលប្រទេសនេះបានដាក់នៅក្នុងប្រាសាទនេះ ឬក៏នៅជុំវិញប្រាសាទ ដែលស្ថិតនៅក្នុងទឹកដី របស់ប្រទេសកម្ពុជា ។*

*ដោយសម្លេង៧ទល់នឹង៥ តុលាការបានសម្រេចថា ប្រទេសថៃឡង់ត្រូវតែប្រគល់មកឲ្យប្រទេសកម្ពុជាវិញ នូវរូបចម្លាក់ សិលាចារឹក បំណែកនៃបូជនីយដ្ឋាន រូបសំណាកធ្វើអំពីថ្មភក់ និងគ្រឿងបានផ្ទាំងធ្វើអំពីដីនានា ដែលចាប់តាំងពីពេលដែលប្រាសាទនេះ ត្រូវបានកាន់កាប់ដោយប្រទេសថៃឡង់ ពីឆ្នាំ១៩៥៤មក អាចនឹងត្រូវក្រសួងមានសមត្ថកិច្ចរបស់ប្រទេសនេះ យកចេញពីប្រាសាទនេះ ឬមួយយកពីក្នុងតំបន់ប្រាសាទនេះទៅ ។*

*លោក តាណាកា និងលោក ម៉ូរែល្លី ជាចៅក្រម បានភ្ជាប់ទៅនឹងសាលដីកានេះ នូវសេចក្តីថ្លែងការណ៍រួមមួយ ។ លោក អាល់ហ្វារ៉ូ អនុប្រធាន និង ស៊ើរ ហ្សេរ៉ាល់ដ៍ ហ្វិត្សម៉ូរិស ចៅក្រម បានភ្ជាប់នឹងសាលដីកានេះ នូវសេចក្តីរាយការណ៍ពីមតិរបស់លោកផ្ទាល់ ។ លោក ម៉ូរ៉េណូ កាំងតាណា លោក វែល្លិងតុន គូ និង ស៊ើរ ប៉ែរស៊ី ស្ពិនដែរ ចៅក្រម បានភ្ជាប់នឹងសាលដីកានេះ នូវសេចក្តីរាយការណ៍មិនយល់ស្រប របស់លោករៀងខ្លួន ។*

*

*      *

*នៅក្នុងសាលក្រមរបស់តុលាការនេះ តុលាការបានសង្កេតឃើញថា ទំនាស់មានមូលហេតុ បេញមកពីបញ្ហាអធិបតេយភាពលើតំបន់ប្រាសាទព្រះវិហារ ។ បដិសរណដ្ឋានបុរាណនេះ ដែលបាក់បែកដោយអន្ទើហើយ ត្រូវបានសង់ឡើងនៅលើកំពូលមួយ នៃជួរភ្នំដងរែក ដែលជាព្រំប្រទល់រវាងប្រទេសកម្ពុជានិងប្រទេសថៃឡង់ ។ ទំនាស់គ្នានេះ មានដើមកំណើត ពីការកំណត់ព្រំដែនដែលបានធ្វើឡើង ពីឆ្នាំ១៩០៤ដល់១៩០៨ រវាងប្រទេសបារាំង ជាអ្នករ៉ាប់រងកិច្ចការបរទេសរបស់ឥណ្ឌូចិន និងប្រទេសសៀម ជាពិសេសក្នុងការអនុវត្តន៍ អនុសញ្ញាចុះថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ ១៩០៤ ។*

*អនុសញ្ញានេះបានកំណត់ជាទូទៅ នូវព្រំដែនមួយ ដែលគំនូសច្បាស់លាស់នឹងត្រូវធ្វើឡើង ជាបន្ទាប់មកទៀត ដោយគណៈកម្មការបម្រុះបារាំង-សៀមមួយ ។*

*នៅផ្នែកខាងកើតភ្នំដងរែក ដែលមានប្រាសាទព្រះវិហារនោះ បន្ទាត់ព្រំដែនត្រូវគូស ឲ្យស្របតាមបន្ទាត់បែកទឹកគ្នា ។ ដើម្បីធ្វើការកំណត់ព្រំដែននេះ ក្នុងពេលប្រជុំមួយដែលបានធ្វើនៅថ្ងៃទី២ ខែធ្នូ ១៩០៦ អង្គប្រជុំបានសម្រេចថា គណកម្មការបម្រុះនេះ ត្រូវធ្វើដំណើរទៅតាមខ្សែកំពូលភ្នំដងរែក ហើយធ្វើការពិនិត្យកត់ត្រា យកការណ៍គ្រប់បែបយ៉ាង តាមសេចក្ដីត្រូវការ ហើយនាយទាហានបច្ចេកទេសខាងផែនទីម្នាក់ របស់ភាគីបារាំងនៃគណកម្មការបម្រុះនេះ នឹងធ្វើការកត់ត្រាទាំងអស់ នៅលើផ្នែកខាងកើតនៃជួរភ្នំនេះ ។*

*ពុំមានភាគីណាមួយប្រកែក អំពីការណ៍ដែលប្រធានទាំងពីរ (នៃគណកម្មការបម្រុះនេះ) ទាំងខាងភាគីបារាំង និងខាងភាគីសៀម បានធ្វើដំណើររួមគ្នាទៅភ្នំដងរែក ដូចគេបានសំរេចរួចមកហើយនោះទេ ហើយនៅក្នុងដំណើរនោះទៀត គេក៏បានចូលទៅមើលប្រាសាទព្រះវិហារនោះផង ។ មួយវិញទៀត នៅក្នុងខែមករា-កុម្ភៈ ឆ្នាំ១៩០៧ ប្រធានផ្នែកភាគីបារាំងបានរាយការណ៍ ដល់រដ្ឋាភិបាលរបស់ខ្លួន ថាគំនូសព្រំដែន ត្រូវបានធ្វើរួចបច់សព្វគ្រប់ហើយ ។ ហេតុនេះ គេអាចយល់បានច្បាស់ថា គំនូសព្រំដែនមួយត្រូវបានកំណត់ដោយហ្មត់ចត់រួចហើយ ទោះបីពុំមានសំណៅស្ដីអំពីសេចក្ដីសំរេចណាមួយ និងពុំមានកំណត់ណាមួយបានចែងអំពីភ្នំដងរែក នៅក្នុងកំណត់ហេតុនៃកិច្ចប្រជុំនានា របស់គណកម្មការបម្រុះ ដែលបានធ្វើជាបន្ទាប់ក្រោយពីថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩០៦នោះក៏ដោយ ។ មួយវិញទៀត នៅពេលដែលគណកម្មការបម្រុះបានប្រជុំគ្នា ដើម្បីបញ្ចប់ការងារនៃកិច្ចការនេះ គេបែរជាបានយកចិត្តទុកដាក់ ទៅលើសន្និសញ្ញាមួយទៀតវិញ គឺសន្និសញ្ញាស្ដីពីព្រំដែនបារាំង-សៀម ចុះថ្ងៃទី ២៣ មិនា ១៩០៧ ។*

*កិច្ចការចុងក្រោយបំផុត ដែលគេត្រូវធ្វើនៅក្នុងការកំណត់ព្រំដែន គឺការរៀបចំផែនទីមួយច្បាស់ ។ រដ្ឋាភិបាលសៀម ដោយសារពុំមានមធ្យោបាយបច្ចេកទេសគ្រប់គ្រាន់ ក៏បានសុំឲ្យនាយទាហានបារាំងរៀបចំផែនទីនានា នៃតំបន់ព្រំដែននោះផង ។*

ផែនទីទាំងនោះ ក៏ត្រូវបានរៀបចំឡើង នៅក្នុងពេលសរទរដូវ នៃឆ្នាំ១៩០៧ ដោយក្រុមនាយទាហានបារាំង ដែលមួយចំនួនជាសមាជិកនៃគណកម្មការបម្រុះផង ហើយក្រោយមក គេបានបញ្ជូនផែនទីទៅដល់រដ្ឋាភិបាលសៀម ក្នុងឆ្នាំ១៩០៨ ។ ក្នុងចំណោម ផែនទីទាំងនោះ មានផែនទីភ្នំដងរែកមួយ ដែលមានគូសប្រាសាទព្រះវិហារ នៅក្នុងទឹកដីរបស់ប្រទេសកម្ពុជា ។ គឺនៅលើផែនទីនេះហើយ (ក្នុងឧបសម្ព័ន្ធ១ នៃអនុស្សរណៈប្រទេសកម្ពុជា) ដែលប្រទេសកម្ពុជាបានយកជាមូលដ្ឋាន ក្នុងការទាមទារអធិបតេយ្យភាពរបស់ខ្លួន លើប្រាសាទ(ព្រះវិហារ)នេះ ។ ប៉ុន្តែប្រទេសថៃឡង់បានថ្លែងថា ដោយសារផែនទីនេះ ពុំមែនជាផែនទី ដែលគណកម្មការបម្រុះជាអ្នកធ្វើ ផែនទីនេះពុំមានលក្ខណៈជាកាតព្វកិច្ច (caractère obligatoire) ទេ (និង) ថាផែនទីនេះបានបញ្ជាក់ពីព្រំដែនមួយ ដែលមិនស្របទៅតាមបន្ទាត់បែកទឹកគ្នា ហើយថាបើគេយកតាមបន្ទាត់នេះវិញ ប្រាសាទព្រះវិហារត្រូវឋិតនៅក្នុងប្រទេសថៃឡង់ (និង)ថាផែនទីនេះ ពុំដែលត្រូវបានទទួលស្គាល់ដោយប្រទេសថៃឡង់ទេ (ហើយ) បើទោះជាប្រទេសថៃឡង់បានយល់ព្រមនិងផែនទីនោះ ក៏ដោយសារប្រទេសថៃឡង់បានសន្និដ្ឋានដោយប្រឡំថា គំនូសព្រំដែននៅលើផែនទីនោះ ប្រាកដជាស្របតាមបន្ទាត់បែកទឹកគ្នា ។

ផែនទីនៅក្នុងឧបសម្ព័ន្ធ១ ពុំដែលត្រូវបានយល់ព្រមតាមពិធីការ ដោយគណកម្មការបម្រុះនោះមែន ដោយនៅពេលនោះ គណកម្មការបម្រុះលែងមានដំណើរការទៅមុខទៀត អស់ជាច្រើនខែរួចមកហើយ មុននឹងផែនទីនេះត្រូវបានរៀបចំឡើង ។ ទោះបីគេមិនអាចសង្ស័យបាន ថាការគូសផែនទីទាំងនេះ ត្រូវបានធ្វើឡើងនៅលើមូលដ្ឋានការងារ នៅលើភ្នំដងរែក របស់ក្រុមនាយទាហានផ្នែកខាងផែនទីក្តី ក៏នៅពេលដំបូង តុលាការបានសន្និដ្ឋានថា ផែនទីនេះពុំទាន់មានលក្ខណៈជាកាតព្វកិច្ចដែរ ។ ប៉ុន្តែ បើតាមសំណុំរឿង ផែនទីទាំងនេះត្រូវបានគេបញ្ជូនទៅឲ្យរដ្ឋាភិបាលសៀម ថាជាលទ្ធផលនៃកិច្ចការទាំងអស់នៃការកំណត់ព្រំដែននេះ (ហើយ) ដោយសារអាជ្ញាធរសៀមពុំមានប្រតិកម្មអ្វីទាំងអស់ នៅសម័យនោះក្តី និងក្នុងពេលច្រើនឆ្នាំបន្ទាប់មកទៀតក្តី គេត្រូវយល់ថាគឺជាការទទួលយល់ព្រម ដោយរដ្ឋាភិបាលសៀមហើយ ។ លើសពីនេះទៅទៀត ផែនទីទាំងអស់នេះ ត្រូវបានផ្តល់ដល់គ្រប់សមាជិកទាំងអស់ នៃភាគីសៀមនៃគណកម្មការបម្រុះ ហើយអ្នកទាំងនោះឥត បានបន្លឺ(នូវសេចក្តីជំទាស់)អ្វីទេ (និង)ត្រូវបានបញ្ជូនដល់ព្រះអង្គម្ចាស់ ដំរុង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃសៀម ហើយលោកបានទាំងថ្លែងអំណរគុណដល់រដ្ឋមន្ត្រីបារាំងនៅក្រុងបាងកក អំពីកិច្ចការហ្នឹងផង (ព្រមទាំង)ត្រូវបានបញ្ជូនទៅឲ្យរាល់ចៅហ្វាយខេត្តទាំងអស់របស់សៀម ដែលមានខ្លះស្គាល់ប្រាសាទព្រះវិហារយ៉ាងច្បាស់លាស់ ថែមទៀតផង ។ ប្រសិនបើអាជ្ញាធរសៀម បានទទួលពិនិត្យហើយ នូវផែនទីដែលមាននៅក្នុងឧបសម្ព័ន្ធ១នេះ ហើយពុំបាធ្វើការស្រាវជ្រាវ ឲ្យបានដឹងពិតប្រាកដនោះទេ អាជ្ញាធរសៀមក៏មិនអាចសំអាងក្នុងពេលនេះ អំពីការបំភ័ន្តបន្ទំអ្វីមួយ ឲ្យខ្លួនព្រមទទួលស្គាល់ (ផែនទីនោះ) ឡើយ ។

រដ្ឋាភិបាលសៀម ដែលក្រោយមកក្លាយជារដ្ឋាភិបាលថៃឡង់ ពុំដែលបានលើកជាបញ្ហាអ្វីទាំងអស់ អំពីផែនទីដែលមាននៅក្នុងឧបសម្ព័ន្ធ១ នេះទេ នៅមុនពេលដែលខ្លួនបានធ្វើការចរចា ជាមួយប្រទេសកម្ពុជា នៅទីក្រុងបាងកកកាលពីឆ្នាំ១៩៥៨ ។

ការពិត គឺតាំងពីឆ្នាំ១៩៣៤-១៩៣៥មក គេឃើញមានការកំណត់បំណុចភូមិសាស្ត្រមួយ ដែលបង្ហាញលក្ខណៈប្លែកគ្នា រវាងគំនូសដែលមាននៅលើផែនទីនោះ និងការគូសបន្ទាត់បែកទឹកគ្នា ហើយម្យ៉ាងទៀត ក៏មានការបោះពុម្ពផ្សាយ ដោយគេបានដាក់ប្រាសាទព្រះវិហារនៅក្នុងទឹកដីថៃ ៖ តែទោះបីយ៉ាងនេះក្តី ក៏ប្រទេសថៃឡង់នៅតែប្រើប្រាស់ផែនទីដ៏ទៃៗនោះ ហើយលើសពីនេះទៅទៀត ថែមទាំងបានផ្សព្វផ្សាយផែនទី ដែលដាក់ប្រាសាទព្រះវិហារ នៅក្នុងទឹកដីប្រទេសកម្ពុជាដែរ ។ ដោយឡែកទៀត ក្នុងពេលមានការចរចាគ្នា ស្តីអំពីសន្ធិសញ្ញាបារាំង-សៀម នៃឆ្នាំ១៩២៥ដល់ឆ្នាំ១៩៣៧ ដោយគេបានបញ្ជាក់ថែមទៀត អំពីព្រំប្រទល់ដែលមានពីមុនហើយនោះ និងបន្ទាប់មក នៅឆ្នាំ១៩៤៧ នៅចំពោះមុខគណកម្មការបារាំង-សៀមផ្សះផ្សាគ្នា នៅទីក្រុងវ៉ាស៊ិនតុននោះ ធម្មតាប្រទេសសៀមគួរតែលើកបញ្ហានេះ ដល់គណកម្មការផ្សះផ្សាគ្នា ៖ ប៉ុន្តែប្រទេសនេះឥតបានធ្វើអ្វីទាំងអស់ ។ នេះជាការបញ្ជាក់ជាបញ្ចប់ថា ប្រទេសថៃឡង់បានទទួលយកគំនូសព្រំដែននៅព្រះវិហារ តាមគំនូសដែលមាននៅក្នុងឧបសម្ព័ន្ធ១ នេះហើយ ទោះបីគំនូសនេះស្របឬមិនស្របនិងបន្ទាត់បែកទឹកគ្នាក្តី ។ ប្រទេសថៃឡង់ដែលសំអាងថា នៅគ្រប់កាលសម័យពីបាកទាំងអស់ ប្រាសាទព្រះវិហារនេះឋិតក្នុងកម្មសិទ្ធិរបស់ខ្លួន ហេតុដូចនេះ ខ្លួនមិនចាំបាច់អ្វីនឹងលើកពីបញ្ហានេះទេ (ហើយ) ប្រទេសថៃឡង់ថែមទាំងបានបង្ហាញ (ដល់តុលាការ) នូវកិច្ចការផ្សេងៗ ដែលរាជ-ការថៃបានធ្វើនៅក្នុងតំបន់នេះ ជាភស្តុតាង ថាប្រទេសថៃមិនដែលបានព្រមទទួល យកការកំណត់ព្រំដែន តាមឧបសម្ព័ន្ធ១ នោះទេ ។ ប៉ុន្តែតុលាការបានវិនិច្ឆ័យថា ជាការពិបាកនិងទទួលស្គាល់ណាស់ ថាកិច្ចការទាំងអស់នោះ ដែលបានធ្វើឡើងដោយរាជការជនបទរបស់ថៃឡង់ អាចលុបបំបាត់នូវឥរិយាបទជានិរន្ត (នៃការទទួលយក) នៃអាជ្ញាធរកណ្តាល (autorités centrales) របស់ប្រទេសថៃឡង់ ។ ការណ៍មួយទៀត នៅក្នុងឆ្នាំ១៩៣០ ក្នុងពេលដែលព្រះអង្គម្ចាស់ ដំរុង បានទៅធ្វើទស្សកិច្ចនៅប្រាសាទនោះ លោកត្រូវបានទទួលជាផ្លូវការ ដោយអ្នកតំណាងបារាំង ដែលប្រចាំការក្នុងខេត្តរបស់ប្រទេសកម្ពុជា ក៏ពេលនោះ ប្រទេសសៀមឥតមានប្រតិកម្ម អ្វីទេ ។

ដោយសារហេតុដែលបានរៀបរាប់មកខាងលើនេះ តុលាការសន្និដ្ឋានថា ប្រទេសថៃឡង់បានទទួលស្គាល់រួចហើយ នូវផែនទីនៃឧបសម្ព័ន្ធ១នេះ ។ ហើយបើទោះបីមានការសង្ស័យណាមួយក្តី ក៏ប្រទេសថៃឡង់ មិនអាចនឹងប្រកែកនៅពេលនេះ ពីការទទួលស្គាល់របស់ខ្លួនបាននោះឡើយ ដោយហេតុថា ទាំងប្រទេសបារាំង ទាំងប្រទេសកម្ពុជា បានជឿនិងទុកចិត្តនៅលើការទទួលស្គាល់របស់ប្រទេសសៀម ហើយក្នុងរយៈកាល៥០ឆ្នាំកន្លងមកនេះ ខាងប្រទេសថៃឡង់ ក៏បានទាញយកអត្ថប្រយោជន៍ដែលអនុសញ្ញាឆ្នាំ ១៩០៤នេះ បានផ្តល់ឲ្យដែរ ។ ដោយឡែកទៀត ក្នុងបទបញ្ញត្តិនៃការអនុវត្តិន៍អនុសញ្ញានេះ ក៏មានភ្ជាប់ផែនទីដែលមាននៅក្នុងឧបសម្ព័ន្ធ១ ជាមួយដែរ ហើយភាគីទាំងអស់ នៅក្នុងពេលនោះ ក៏បានធ្វើការបកស្រាយនៃបទបញ្ញត្តិនៃការអនុវត្តិន៍នោះ ដោយទុកព្រំប្រទល់ដែន ដែលមានគូសនៅលើផែនទី ឲ្យមានប្រៀបទៅលើបទបញ្ញត្តិនានានៃអនុសញ្ញា ហើយដោយសារគ្មានអ្វីមួយ ដែលធ្វើឲ្យគេយល់ថា ភាគីទាំងពីរបានដាក់តម្លៃជាពិសេសណាមួយ ទៅលើបន្ទាត់បែកទឹកគ្នា

*នោះ បើ ប្រៀបទៅនិងសារៈសំខាន់ធំបំផុតចំពោះខ្លួន ក្នុងការរកដំណោះស្រាយពីបញ្ហាព្រំដែនទេ ហេតុនេះតុលាការយល់ថា ការបកស្រាយដែលត្រូវធ្វើនៅបច្ចុប្បន្ននេះ គឺត្រូវតែធ្វើដូចគ្នានិងសេចក្ដីខាងលើដដែល ។*

*អាស្រ័យហេតុនេះ តុលាការយល់ថា ការចាំបាច់ត្រូវកាត់សេចក្ដីដោយផ្ដល់តម្លៃ ទៅលើព្រំប្រទល់ដែលមាននៅក្នុងឧបសម្ព័ន្ធ ១ នៃតំបន់ទាស់គ្នានេះ ហើយមិនមានប្រយោជន៍អ្វីនឹងពិនិត្យមើលថា តើបន្ទាត់ព្រំដែនហ្នឹង ស្របឬមិនស្របទៅនឹង បន្ទាត់បែកទឹកភ្នា ពិតប្រាកដ នោះឡើយ ។*

*ដោយហេតុទាំងអស់នេះ តុលាការសំរេចប្រគល់ដល់ប្រទេសកម្ពុជា នូវអធិបតេយ្យភាពលើ ប្រាសាទព្រះវិហារ ៕*

---